002/19-09-2007-ECCC/TC
E1/134

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 13 / 12 / 2012
ម៉ោង (Time/Heure) : 14 : 50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ព្រហស្បត្តិ៍ ទី ១៨ ខែ តុលា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី- ថ្ងៃទី ១២១

រៀបចំដោយ: ឌុច ផារី និង Roger PHILLIPS

| <u>កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ</u> |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក Roger PHILLIPS, លោកស្រី សែ កុលវុឌ្ឍី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Vincent DE WILDE D'ESTMAEL, លោក Keith RAYNOR, កញ្ញា សុង ឆវ័ន្ត, លោក ច័ន្ទ តារាវស្មី |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZZI, |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក សំ សុគង់, លោក វ៉ែន ពៅ |
| សាក្សី៖ (មិនមាន) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ កញ្ញា Eleanor DOYLE-MARKWICK |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០២ | បញ្ចប់ម៉ោង៖ ១៦.០៧ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៤១ | បញ្ចប់ម៉ោង៖ ១១.០១ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣៦ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤១ | បញ្ចប់ម៉ោង៖ ១៥.១១ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ៤០ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សំណើសុំធ្វើសេចក្តីថ្លែងការណ៍ទាក់ទងនឹងការយាងចូលទិវង្គត់របស់អតីត មហាវីរក្សត្រព្រះបាទសម្តេច នរោត្តម សីហនុ | មេធាវីការពារក្តី នួន ជា | ៩.០៣ | ៩.០៤ |
| សំណើរបស់មេធាវីការពារក្តី នួន ជា ស្នើសុំការបញ្ជាក់អំពីទម្ងន់នៃភស្តុតាងដែលបានធ្វើការកត់សម្គាល់ដោយជនជាប់ចោទ | មេធាវីការពារក្តី នួន ជា | ៩.០៤<br>១៥.១៤ | ៩.០៨<br>១៥.១៦ |
| សំណើរបស់មេធាវីការពារក្តី នួន ជា ស្នើសុំដកស្រង់នូវខ្លឹមសារដែលមាននៅក្នុងអត្ថបទសារព័ត៌មាន | មេធាវីការពារក្តី នួន ជា | ៩.០៨<br>១២.០១ | ៩.១១<br>១២.០៣ |
| ការដាក់បង្ហាញឯកសារទាក់ទងនឹងរចនា | សហព្រះរាជអាជ្ញា | ៩.១១ | ១២.០១ |

| | | | |
|---|---|---|---|
| សម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យនៅចំពោះមុខអង្គជំនុំជម្រះ | សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ១៣.៣៦<br>១៥.១៦ | ១៤.០០<br>១៦.០៦ |
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្ដី នួន ជា | ១២.០៣ | ១២.០៥ |
| ការជំទាស់តវ៉ាទៅលើឯកសារទាក់ទងនឹងសហករណ៍ | មេធាវីការពារក្ដី ខៀវ សំផន | ១៥.៥៥ | ១៥.៥៨ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>សំណើសុំធ្វើសេចក្ដីថ្លែងការណ៍ទាក់ទងនឹងការយាងចូលទីវង្គត់របស់អតីត មហាវីរ ក្សត្រ ព្រះបាទសម្ដេច នរោត្តម សីហនុ</u>**

មេធាវីការពារក្ដី នួន ជា ក្នុងនាមកូនក្ដីរបស់គាត់ ស្នើសុំធ្វើសេចក្ដីថ្លែងការណ៍ទាក់ទងនឹងការយាងចូលទីវង្គត់របស់អតីត មហាវីរ ក្សត្រព្រះបាទសម្ដេច នរោត្តម សីហនុ។ អង្គជំនុំជម្រះសម្រេចបដិសេធលើសំណើសុំ។

**<u>សំណើរបស់មេធាវីការពារក្ដី នួន ជា ស្នើសុំការបញ្ជាក់អំពីទម្ងន់នៃភស្តុតាងដែលជនជាប់ចោទបានធ្វើការកត់សម្គាល់</u>**

មេធាវីការពារក្ដី នួន ជា ស្នើសុំការបញ្ជាក់ពីអង្គជំនុំជម្រះអំពីទម្ងន់នៃភស្តុតាង ដែលជនជាប់ចោទធ្វើការកត់សម្គាល់ តែជនជាប់ចោទមិនឆ្លើយតបទៅនឹងសំណួរ ឬមិនបានលះបង់នូវសិទ្ធិនៅស្ងៀមរបស់ខ្លួន ។

អង្គជំនុំជម្រះរំឭកឡើងវិញនូវសេចក្ដីសម្រេចរបស់ខ្លួន ដែលថាឯកសារដែលបានធ្វើការកត់សម្គាល់ដោយជនជាប់ចោទមិនមានទម្ងន់ជាភស្តុតាងខ្លាំងនោះទេ លើលលែងតែជនជាប់ចោទយល់ព្រមឆ្លើយតបទៅនឹងសំណួរលើប្រធានបទជាក់លាក់ណាមួយ។ ទោះជាយ៉ាងណា តម្លៃនៃភស្តុតាងចំពោះឯកសារដែលបានធ្វើការកត់សម្គាល់ដោយជនជាប់ចោទនោះនឹងត្រូវវាយតម្លៃដោយផ្អែកតាមវិធានផ្ទៃក្នុង និងភស្តុតាងផ្សេងទៀតដែលបានដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ ។

**<u>សំណើរបស់មេធាវីការពារក្ដី នួន ជា ស្នើសុំប្រើនូវអត្ថបទសារព័ត៌មាន</u>**

មេធាវីការពារក្ដី នួន ជា ស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីយោងទៅលើអត្ថបទមួយដែលបាននិពន្ធ

ដោយ Glenys Kinnock នៅក្នុងកាសែត International Herald Tribune ។ អង្គជំនុំជម្រះសម្រេចបដិសេធលើការស្នើសុំ ព្រោះអត្ថបទនោះមិនមានភាពពាក់ព័ន្ធ ។ មេធាវីការពារក្តី នួន ជា ស្នើសុំការបញ្ជាក់ថាតើចៅក្រមនៃអង្គជំនុំជម្រះបានអានអត្ថបទនោះដែរឬទេ។ អង្គជំនុំជម្រះបានបញ្ជាក់ប្រាប់ដល់មេធាវីការពារក្តី នួន ជា ថា ប្រសិនបើមេធាវីមានបំណងលើកយកអត្ថបទនេះមកពិភាក្សាដេញដោល មេធាវីត្រូវអនុវត្តតាមវិធាន ៨៧(៤) និង ៨៧ (៣) ទាក់ទងនឹងនីតិវិធីនៃការទទួលយកភស្តុតាងថ្មី ។

**<u>ការដាក់បង្ហាញឯកសារទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យនៅចំពោះមុខអង្គជំនុំជម្រះ</u>**

សហព្រះរាជអាជ្ញាបញ្ចប់ការដាក់បង្ហាញឯកសារ ដែលសហព្រះរាជអាជ្ញាយល់ថាមានភាពពាក់ព័ន្ធបំផុតទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់មកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចាប់ផ្តើមដាក់បង្ហាញឯកសារទាក់ទងនឹងប្រធានបទទាំងពីរខាងលើនៅចំពោះមុខអង្គជំនុំជម្រះ ។

**<u>ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់</u>**

ជនជាប់ចោទ នួន ជា (ម៉ោង ១២.០៣) តាមរយៈមេធាវីរបស់គាត់ ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់សម្រាប់ពេលរសៀល ។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមការស្នើសុំ។

**<u>ការជំទាស់តវ៉ានឹងឯកសារដែលបានស្នើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

មេធាវីការពារក្តី អៀង សារី ស្នើសុំមិនឱ្យអង្គជំនុំជម្រះទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ០៥ ដែលមានក្នុងបញ្ជីឯកសាររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១២) ដើម្បីយកមកពិភាក្សាដេញដោលនោះទេ។ មេធាវីការពារក្តី អៀង សារី បានលើកឡើងថាឯកសារទាំងនោះគឺជាឯកសារដែលរំលោភទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះពីមុន ដែលថាសេចក្តីថ្លែងការណ៍ជាលាយលក្ខអក្សរណ៍ ដែលបានដាក់បង្ហាញជំនួសឱ្យសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់គឺមិនអាចទទួលយកបានទេ ប្រសិនបើប្រសិនសេចក្តីថ្លែងការណ៍នោះបញ្ជាក់ពីទង្វើជាក់លាក់ណាមួយរបស់ជនជាប់ចោទ ។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានកត់សម្គាល់ថា បញ្ជីឯកសារដែលមេធាវីការពារក្តី

00869180



អៀង សារី បានលើកឡើងនោះគឺជាបញ្ជីចាស់ ចំពោះបញ្ជីថ្មីមេធាវីនាំមុខបានចែកចូនដល់ភាគីទាំងអស់រួច ហើយ នៅថ្ងៃនេះ។ សហមេធាវីនាំមុខក៏បានយល់ព្រមដកនូវឯកសារចំនួនពីរ ដែលជាកំណត់ហេតុស្តាប់យកចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីពីររូបផងដែរ ព្រោះឯកសារទាំងនោះអាចធ្វើឲ្យមានបញ្ហាដល់អង្គជំនុំ-ជម្រះ។

អង្គជំនុំជម្រះបញ្ជាក់ថា អង្គជំនុំជម្រះនឹងយោងតែទៅលើបញ្ជីឯកសារចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១២ ប៉ុណ្ណោះ មិនមែនបញ្ជីឯកសារចុះថ្ងៃទី១៨ ខែ តុលា ឆ្នាំ ២០១២ នោះទេ ពីព្រោះឯកសារចុះថ្ងៃទី១១ ខែ តុលា ឆ្នាំ ២០១២ គឺជាឯកសារមួយដែលបានជូនដំណឹងយ៉ាងសមរម្យដល់គ្រប់ភាគី ។ ប៉ុន្តែ អង្គជំនុំជម្រះនឹងដកនូវឯកសារចំនួនពីរដែលមិនមាននៅក្នុងបញ្ជីឯកសារទីពីរ។ បន្ថែមលើនេះ អង្គជំនុំជម្រះនឹងដកនូវឯកសារចំនួនពីរដែលជាកំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សីចេញពីបញ្ជីរបស់សហមេធាវីនាំមុខ។ ទាក់ទងនឹងការជំទាស់របស់មេធាវីការពារក្តី អៀង សារី ទៅលើឯកសារ អង្គជំនុំជម្រះបញ្ជាក់ថា អង្គជំនុំជម្រះមិនទាន់អាចចេញសេចក្តីសម្រេចលើបញ្ហានេះបានទេ តែអង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចលើបញ្ហានេះនៅពេលក្រោយ ។

**<u>ការជំទាស់តវ៉ាអំពីភាពពាក់ព័ន្ធនៃឯកសារអំពីសហករណ៍</u>**

មេធាវីការពារក្តី ខៀវ សំផន ជំទាស់តវ៉ាទៅលើឯកសារដែលបានស្នើសុំដាក់ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ព្រោះឯកសារទាំងនោះមិនមានភាពពាក់ព័ន្ធទៅនឹងប្រព័ន្ធទំនាក់ទំនងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះបានណែនាំទៅភាគីមិនឲ្យធ្វើការពិភាក្សាលម្អិតទៅលើអង្គហេតុស្តីពីសហករណ៍ នោះទេ ប៉ុន្តែអនុញ្ញាតឲ្យមេធាវីនាំមុខបន្តការដាក់បង្ហាញឯកសារ ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| TC Ref Number | OCIJ Ref Number | Name/Description | Party/TC | Remarks (ERN) |
|---|---|---|---|---|
| E3/1568 | | អត្ថបទដែលបានវាយសារឡើងវិញពីអត្ថបទសរសេរដោយដៃនៃបទសម្ភាសន៍ជាមួយ ជា ស៊ីម ថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ១៩៩១ និង ហេង សំរិន ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ១៩៩១ នៅទីក្រុងភ្នំពេញ | មេធាវីការពារក្តី នួន ជា | |

| | | | | |
|---|---|---|---|---|
| E3/781 | | ឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា "ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក" | មេធាវីការពារក្តី នួន ជា | |
| E3/488 | | ឧបសម្ព័ន្ធ ០០០០៣៖ AKI ស្វាគមន៍ សមាគមមិត្តភាព និងទំនាក់ទំនងរវាងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា | មេធាវីការពារក្តី នួន ជា | |
| | D366/7.1.351 | កិច្ចប្រជុំ របាយការណ៍ជូន ខៀវ សំផន នៅថ្ងៃទី ១ កក្កដា ១៩៧៨ ស្តីពីការប្រជុំជាមួយមិត្តចិន | សហព្រះរាជអាជ្ញា | 00188509-10(KH); 00548785-86(FR); 00574558 (EN) |
| | D366/7.1.487 | សេចក្តីរាយការណ៍ អំពីស្រូវ អង្គ ពី ១-៧ មិនា ៧៧ | សហព្រះរាជអាជ្ញា | |
| | IS18.68 | រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យស្ថិតិនាំចូល ឆ្នាំ ១៩៧៨ | សហព្រះរាជអាជ្ញា | |
| E3/1159 | | សេចក្តីរាយការណ៍របស់សន្និបាតក្រសួង ២៥-២៦ កក្កដា ៧៦ | សហព្រះរាជអាជ្ញា | 00188204-05(KH); 00665460-61(FR); 00701587 (EN) |
| E3/522 | | សៀវភៅកំណត់ហេតុរបស់ អៀង សារី ឆ្នាំ ១៩៧៦-៧៩ | សហព្រះរាជអាជ្ញា | |
| E3/808 | | កម្ពុជាប្រជាធិបតេយ្យ កិច្ចប្រជុំរបស់ក្រសួងសង្គមកិច្ច "របាយការណ៍កិច្ចប្រជុំរួម ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧៨" | សហព្រះរាជអាជ្ញា | |

| | | | | |
|---|---|---|---|---|
| E3/153 | | ឯកសារក្រសួងពានិជ្ជកម្មកម្ពុប្រជាធិបតេយ្យ ដែលមានចំណងជើងថា "មតិបន្ថែមលើសេចក្តីរាយការណ៍សន្និបាទ ថ្លែងថ្ងៃទី 25-26 កក្កដា 1976" | សហព្រះរាជអាជ្ញា | |
| E3/962 | | ឧបសម្ព័ន្ធ ២៧៖ សេចក្តីសំរេចរបស់គណៈក្រសួងពាណិជ្ជកម្ម | សហព្រះរាជអាជ្ញា | 00333254(EN); 00068577(KH); 00771815(FR) |
| E3/174 | | ក្រសួងពាណិជ្ជកម្មកម្ពុជាប្រជាធិបតេយ្យ គណៈក្រសួងពាណិជ្ជកម្ម មតិយោបល់គ្រប់ផ្នែក ថ្ងៃទី ១៧-១០-១៩៧៦ | សហព្រះរាជអាជ្ញា | |
| E3/846 | | សេចក្តីរាយការណ៍ប្រចាំ ១០ ថ្ងៃ អំពីសភាពការណ៍របស់សត្រូវ មហាជន និង បញ្ហាផ្ទៃក្នុង | សហព្រះរាជអាជ្ញា | |
| | IS16.52/ IS16.53 (same document) | [កែតម្រូវ ១] បញ្ជីឈ្មោះមនុស្សនៅពាណិជ្ជកម្ម ដែលចាប់ហើយពីដើមរហូតដល់ថ្ងៃទី ២៦ មិនា ៧៧ | សហព្រះរាជអាជ្ញា | |
| E3/1641 | | ចម្លើយសារភាពរបស់លោក តាន់ ទ្រី ហៅ ឈឿន អតីតសាស្ត្រាចារ្យជាសមាជិកពាណិជ្ជកម្មរដ្ឋជាភាសាខ្មែរ ចុះថ្ងៃទី ១៧ កុម្ភៈ ១៩៧៧ | សហព្រះរាជអាជ្ញា | |
| E3/235 | | សរុបសេចក្តីសំរេចរបស់គណៈអចិន្ត្រៃយ៍ក្នុងអង្គប្រជុំថ្ងៃ ១៩-២០-២១ មេសា ១៩៧៦ | សហព្រះរាជអាជ្ញា | |
| E3/153 | | ឯកសារក្រសួងពានិជ្ជកម្មកម្ពុប្រជាធិបតេយ្យ ដែលមានចំណងជើងថា "មតិបន្ថែមលើសេចក្តីរាយការណ៍ | សហព្រះរាជអាជ្ញា | |

00869183



| | | | | |
|---|---|---|---|---|
| | | សន្និបាទ ថ្លែងថ្ងៃទី 25-26 កក្កដា 1976" | | |
| | IS16.50 | ស្ថិតិអ្នកទោសដែលកំពុងសួរបន្តពីខែមុន | សហព្រះរាជអាជ្ញា | |
| | D82/II-Annex 42 | របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី០៤ មីនា ២០០៨ | សហព្រះរាជអាជ្ញា | |
| E3/226 | | កំណត់ហេតុប្រជុំការងារ សង្គមកិច្ច សុខាភិបាល ថ្ងៃទី ១០ មិថុនា ១៩៧៦ | សហព្រះរាជអាជ្ញា | 0017154-55(KH); 00296163(FR); 00183368-69(EN) |
| E3/808 | | កម្ពុជាប្រជាធិបតេយ្យ កិច្ចប្រជុំរបស់ក្រសួងសង្គមកិច្ច "របាយការណ៍កិច្ចប្រជុំរួម ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧៨" | សហព្រះរាជអាជ្ញា | 0000534(KH); 00811290(FR); 00197599(EN); 0000549(KH); 00811297(FR); 00197614 (EN) |
| E3/231 | | កំណត់អង្គប្រជុំការងារឃោសនាការថ្ងៃ ៨ មិនា ១៩៧៦ | សហព្រះរាជអាជ្ញា | |
| E3/225 | | កំណត់ហេតុនៃអង្គប្រជុំការងារឃោសនាការថ្ងៃ ១ មិថុនា ១៩៧៦ | សហព្រះរាជអាជ្ញា | |
| E3/182 | | ការប្រជុំអចិន្ត្រៃយ៍ថ្ងៃទី ៩ តុលា ៧៥ | សហព្រះរាជអាជ្ញា | 00019108-19(KH); 00183393-402(EN); 00292868-79(FR) |
| E3/232 | | កំណត់ហេតុនៃអង្គប្រជុំការងារប្រចាំថ្ងៃ ៨ មិនា ១៩៧៦ | សហព្រះរាជអាជ្ញា | |
| E3/216 | | កំណត់ហេតុ អំពីទស្សនកិច្ច អចិន្ត្រៃយ៍ និងសេចក្តីរាយការណ៍អំពីសភាពការណ៍រួមនៅមូលដ្ឋាន | សហព្រះរាជអាជ្ញា | |
| E3/200 | | សន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ច | សហព្រះរាជ | 00292805(KH); 00004165(EN) |

| | | | | |
|---|---|---|---|---|
| | | ប្រជុំគំរប់ខួប នៅថ្ងៃទី ១៥ មេសា ១៩៧៧ | អាជ្ញា | (no French provided) |
| E3/166 | | ទង់បដិវត្ត លេខ 2-3 កុម្ភៈ-មិនា 1976 | សហព្រះរាជអាជ្ញា | 00063210(KH); 00517830(EN); 00492773(FR) |
| E3/12 | | សេចក្ដីសំរេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន | សហព្រះរាជអាជ្ញា | 0003139(KH); 00182812(EN); 00224365(FR) |
| E3/160 | | ឯកសារទំនាក់ទំនងខ្មែរក្រហម ពីឆ្នាំ ១៩៧៥ ដល់ ១៩៧៨ | សហព្រះរាជអាជ្ញា | |
| E3/727 | | ទង់បដិវត្ត លេខពិសេស ឧសភា មិថុនា ១៩៧៨ | សហព្រះរាជអាជ្ញា | |
| E3/1150 | | ជំរាបសមមិត្ត យ៉ា ទីស្នេហា និងរលឹក | សហព្រះរាជអាជ្ញា | |
| E3/241 | | ទូរលេខ ៥២៖គោរពជូនអង្គការ ៨៧០ ជាទីស្នេហា និងរលឹក អំពីសភាពការណ៍ខ្មាំងតាមព្រំដែនថៃ | សហព្រះរាជអាជ្ញា | 00020908(KH); 00183627(EN); 00335192(FR) |
| E3/1091 | | ទូរលេខ ៥៣៖ គោរពជូនគណៈ ៨៧០ ជាទីគោរពស្នេហា និងនឹករលឹក | សហព្រះរាជអាជ្ញា | |
| E3/1144 | | ទូរលេខ ៦០៖ គោរពជូនគណៈ ៨៧០ ជាទីស្នេហា និងនឹករលឹក អំពីសភាពការណ៍គ្រប់ផ្នែកមួយចំនួន | សហព្រះរាជអាជ្ញា | |
| E3/1073 | | ទូរលេខ លេខ 324 ចុះថ្ងៃទី 10-04-1978 | សហព្រះរាជអាជ្ញា | 00293359(EN); 00630816-17(FR) (no Khmer ERN provided) |
| E3/801 | | កំណត់ហេតុនៃការប្រជុំការងារបង្កើនផល សភាពការណ៍ខ្មាំង និង សភាពការណ៍បក្ស | សហព្រះរាជអាជ្ញា | 00017183(KH) (no other ERNs provided) |

| | | | | |
|---|---|---|---|---|
| E3/1122 | | ទូរលេខ ៦៩៖ ជូន បង ជាទីគោរព អំពីសភាពការណ៍នៅស្រុក ៥១ | សហព្រះរាជអាជ្ញា | |
| E3/319 | | ការប្រើប្រាស់ ឥណទាន ១៤០ លានយាន់ថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៧៨ | សហព្រះរាជអាជ្ញា | |
| E3/943 | | ទូរលេខ ០៩៖ គោរពជូន បង ជាទីគោរព អំពីសភាពការណ៍តាមព្រំដែនជុំវិញផ្លូវលេខ ១៩ | សហព្រះរាជអាជ្ញា | |
| E3/1191 | | ជូនមិត្ត ខឿន ជាទីស្នេហានិងរលឹក | សហព្រះរាជអាជ្ញា | |
| E3/1192 | | ទូរលេខ ២ ជូនបង នួន | សហព្រះរាជអាជ្ញា | |
| E3/257 | | មក ម. ៨៧០ ជាទីស្នេហា | សហព្រះរាជអាជ្ញា | |
| E3/879 | | ទូរលេខរបាយការណ៍ លេខ៤៥ ស្តីពីសេចក្តីរាយការណ៍នៅតាមព្រំដែនតំបន់២៣របស់ ឌុន ទៅកាន់ បុល ពត | សហព្រះរាជអាជ្ញា | |
| E3/871 | | ទូរលេខ ២១ គោរពជូនស.មបង ប៉ុល: សេចក្តីរាយការណ៍របស់ស.ម ឈូក តំបន់២៤ ស្តីពីសភាពការណ៍នៅតាម | សហព្រះរាជអាជ្ញា | |
| E3/892 | | ទូរលេខ ៦០ ៖គោរពជូន មន្ទីរ ៨៧០ ជាទិស្នេហា និងរលឹក អំពីសភាពការណ៍នៅតំបន់ ២៣ | សហព្រះរាជអាជ្ញា | |
| E3/769 | | យុវជន និង យុវនារី បដិវត្ត លេខ៤ មេសា ១៩៧៧ | សហព្រះរាជអាជ្ញា | 0005285-86(KH) |
| E3/1094 | | គោរពជូនអង្គការជាទីគោរពស្នេហានឹករលឹក ពីម៤០១ | សហព្រះរាជអាជ្ញា | 0014360-61(KH); 00143607-10(KH); 0014369- |

| | | | | |
|---|---|---|---|---|
| | | | | 12(KH); 00593526-30, 32(FR); 00315371, 0031537-74, 76(EN) |
| E3/1092 | | នអង្គការជាទីគោរពស្នេហានីករលីក ពីម៤០១ | សហព្រះរាជ អាជ្ញា | 00143577-78(KH); 0011447-48(FR) 00289922(EN) |
| E3/1179 | | របាយការណ៍ ម. ៥៦០ តំបន់អាគ្នេយ៍ | សហព្រះរាជ អាជ្ញា | 00214271(KH) |
| E3/951 | | ឯកសារកម្ពុជាប្រជាធិបតេយ្យ មាន ចំណងជើងថា "គោរពជូនអង្គការ ៨៧០" | សហព្រះរាជ អាជ្ញា | 00021043(KH); 00296221(FR); 00185216(EN) |
| E3/1096 | | ទូរលេខមានចំណងជើងថា៖ ទូរលេខ លេខ៣២ | សហព្រះរាជ អាជ្ញា | |
| E3/511 | | ទូរលេខលេខ ៩៤ ជូនបង ប៉ុល: រាយការណ៍ជូនបងពីសភាពការណ៍ ខ្មាំង, មហាជន និងបង្ករបង្កើតផល នៅភូមិភាគឧត្តរ | សហព្រះរាជ អាជ្ញា | |
| E3/239 | | ទូរលេខលេខ ១៦ សូមជំរាបគណ: ៨៧០ ជាទិីគោរពស្នេហា ៖ ខ្ញុំសូម រាយការណ៍ជូនសភាពការណ៍ នៅខេត្តឧត្តរមានជ័យ | សហព្រះរាជ អាជ្ញា | |
| E3/1679 | | ទូរលេខ លេខ១៥ ស្តីពី៖ សូមជំរាបជូន បង ប៉ុល ជាទីគោរព | សហព្រះរាជ អាជ្ញា | |
| E3/956 | | ទូរលេខ៖ ១៤ ជំរាបជូនអង្គការ ជាទីគោរពស្នេហា | សហព្រះរាជ អាជ្ញា | |
| E3/501 | | ឧបសម្ព័ន្ធ ៦៨៖ ទូរលេខ ៩៥ មក ម.៨៧០ ជាទីស្នេហា: សូមរាយការណ៍ | សហព្រះរាជ អាជ្ញា | |

| | | | | |
|---|---|---|---|---|
| | | ពីសភាពការណ៍ខ្មាំង | | |
| E3/178 | | សេចក្តីរាយការណ៍របស់គណៈកម្មាធិការតំបន់៥ ប្រចាំអាទិត្យ ២១ ឧសភា ១៩៧៧ | សហព្រះរាជអាជ្ញា | 00275588-89(KH); 00623326(FR); 00342710(EN); 00275587(KH); 00623305-06(FR); 00342709 (EN) |
| E3/180 | | សេចក្តីរាយការណ៍ អំពីសភាពការណ៍ខ្មាំង, សភាពការណ៍ប្រជាជន, សភាពការណ៍កសាងសង្គមនិយម | សហព្រះរាជអាជ្ញា | |
| E3/1019 | | ឧបសម្ព័ន្ធ ៣៨៖ អំពីវៀតណាមលួចបន្លិតបង្គោលព្រំដែនចូលក្នុងទឹកដីយើង, ភូមិភាគបូព៌ាទិស, តំបន់ ២៣ | សហព្រះរាជអាជ្ញា | |
| E3/1120 | | ទូរលេខ ១០០ ៖ សូមជំរាបបង ញឹម អំពីសភាពការណ៍ខ្មាំងនៅតំបន់ ៥ | សហព្រះរាជអាជ្ញា | |
| | IS18.52 | សេចក្តីរាយការណ៍ជូនអាជ្ញាធរស្រុកត្រាំកក់ អំពីយុវជនថ្មី ធ្វើសកម្មភាពប្រជុំគ្នា | សហព្រះរាជអាជ្ញា | 00079106(KH); 00712134(FR); 00276574(EN) |
| | IS18.44 | របាយណ៍ការជូនទៅមូលដ្ឋានស្រុកត្រាំកក់នៃបក្សកុម្មុយនីស្ត | សហព្រះរាជអាជ្ញា | (No French ERN) 00276590(EN); 00082729-30(KH) |
| | D157.47 | សេចក្តីរាយការណ៍ពីសកម្មភាពឈ្មោះ មូ ផុន នៅឃុំ ញ៉ែញង | សហព្រះរាជអាជ្ញា | |
| | D157.95 | សេចក្តីរាយការណ៍អំពីឈ្មោះ ព្រំ សឿន យុវជនថ្មី | សហព្រះរាជអាជ្ញា | |
| | IS18.26 | សេចក្តីរាយការណ៍ជូនមន្ទីរអប់រំស្រុកត្រាំកក់អំពីឈ្មោះ ពៅ ផាល់ | សហព្រះរាជអាជ្ញា | |
| | D232/78.2 | ឧបសម្ព័ន្ធ២: លិខិតជូនចំពោះសមមិត្ត | សហព្រះរាជ | |

| | | | | |
|---|---|---|---|---|
| | | បឿន នៅថ្ងៃទី១ ខែសីហា ឆ្នាំ១៩៧៧ | អាជ្ញា | |
| E3/859 | | ទូរលេខ ០៥៖ សុំជំរាបមកគណៈ ៨៧០ ជាទីស្នេហា និងរលើក អំពីសភាពការណ៍សមរភូមិផ្លូវលេខ ៧ | សហព្រះរាជអាជ្ញា | |
| E3/1082 | | សេចក្តីរាយការណ៍ថ្ងៃទី ១២ សីហា ៧៧ តាមទូរស័ព្ទសំងាត់ អំពីសភាពការណ៍តាមព្រំដែនថៃ | សហព្រះរាជអាជ្ញា | |
| E3/1289 | | ឧបសម្ព័ន្ធ ១៥៖ ចម្លើយសារភាពរបស់គិញវៀតណាម ម៉ូវ ឈីន ហៅ អាចារ្យ ខ្លាំងប្រកាសតាមវិទ្យុភ្នំពេញ ថ្ងៃទី ០១ កុម្ភៈ ១៩៧៨ | សហព្រះរាជអាជ្ញា | 00224163(KH); 00324920(FR); 00169190(EN) |
| E3/1362 | | ឧបសម្ព័ន្ធ 00041: របាយការណ៍ស្តីពីសេវាផ្សព្វផ្សាយព័ត៌មានបរទេស របាយការណ៍សំរាប់ខែ ឧសភា ឆ្នាំ១៩៧៨ | សហព្រះរាជអាជ្ញា | 00701795(KH); 00701785(FR); 00169986(EN) |
| E96/7 | | សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង | មេធាវីការពារក្តី អៀង សារី | |
| | D368/2 | កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី CHAO Khim ចៅឃឹម | សហមេធាវីនាំមុខ/វេណី | |
| | D199/14 | កំណត់ហេតុនៃការស្តាប់ចម្លើយ LEFEUVRE Martine | សហមេធាវីនាំមុខ/វេណី | |
| | D194 | [កោសលុប] សំណើសុំបំពេញកិច្ចស៊ើបសួរទី១៤របស់សហមេធាវី នួនជា | មេធាវីការពារក្តី អៀង សារី | |

| | | | | |
|---|---|---|---|---|
| | D363 | អនុស្សរណៈស្តីពីការបញ្ជាក់អំពីការតំណាងតាមផ្លូវច្បាប់នៅក្នុងសំណើសុំកិច្ចស៊ើបសួរ | មេធាវីការពារក្តី អៀង សារី | |
| | D22/289 | ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លោក ចៅ ឃីម | មេធាវីការពារក្តី អៀង សារី | |
| | D368/2 | កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី CHAO Khim ចៅ ឃីម | មេធាវីការពារក្តី អៀង សារី | |
| | D22/289.21 | អត្ថបទការសែតដែលមានចំណងជើងថា៖កិច្ចសម្ភាសន៍ជាមួយ ចៅ សេង | មេធាវីការពារក្តី អៀង សារី | |
| | D22/289.11 | ឧបសម្ព័ន្ធ ១១៖ ចៅ សេង សរសេរទៅភរិយានៅបារាំង ពីប៉េកាំង | មេធាវីការពារក្តី អៀង សារី | |
| | D22/289.14 | ឧបសម្ព័ន្ធ ១៤៖ បញ្ជីឈ្មោះអ្នកធ្វើមាតុភូមិនិវត្តពីបរទេស មកកាន់កម្ពុជាប្រជាធិបតេយ្យចន្លោះឆ្នាំ ១៩៧៥ ទៅឆ្នាំ ១៩៧៦ | មេធាវីការពារក្តី អៀង សារី | |
| | D22/44 | ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី LEFEUVRE Martine | មេធាវីការពារក្តី អៀង សារី | |
| | D199/14 | កំណត់ហេតុនៃការស្តាប់ចម្លើយ LEFEUVRE Martine | មេធាវីការពារក្តី អៀង សារី | |
| | D22/44.11 | ឧបសម្ព័ន្ធ ១១: សំបុត្រទូតកម្ពុជាប្រចាំប្រទេសចិនអោយ អ៊ុក កេត ត្រលប់មកកម្ពុជា | មេធាវីការពារក្តី អៀង សារី | |
| | D22/44.13 | ឧបសម្ព័ន្ធ ១៣៖ បញ្ជីឈ្មោះអ្នកទោសកំទេចថ្ងៃទី ៩ ខែធ្នូ ឆ្នាំ៧៧ | មេធាវីការពារក្តី អៀង សារី | |
| E3/1713 | | ឧបសម្ព័ន្ធ ២៖ សៀវភៅនិពន្ធដោយ | មេធាវីការពារក្តី | |

| | | | | |
|---|---|---|---|---|
| | | លោក អុង ថុងហឿង មានចំណងជើងថា "គ្រលប់មើលក្រោយវិញនៃរឿងដ៏សែនខ្លោចផ្សាមួយ" | ខៀវ សំផន | |
| | D22/289.17 | បញ្ជីឈ្មោះជនជាតិខ្មែររស់នៅក្រៅប្រទេស | សហមេធាវីនាំមុខ/វេណី | |
| E186.1R | | ឧបសម្ព័ន្ធ ១៖ ភាពយន្តឯកសារដែលមានចំណងជើងថា៖ "សត្រូវរបស់ប្រជាជន" និងថាសស៊ីឌីពាក់ព័ន្ធ | សហមេធាវីនាំមុខ/វេណី | |
| | IS9.1 | លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា | សហមេធាវីនាំមុខ/វេណី | |
| E101/2.3R | | Video entitled "To Continue 15 to Survive of the Heart of the Khmer Rouge Madness" | សហមេធាវីនាំមុខ/វេណី | |
| E3/123 | | សៀវភៅនិពន្ធដោយ ខៀវ សំផន មានចំណងជើងថា " សេដ្ឋកិច្ចកម្ពុជា និង បញ្ហាឧស្សាហកម្មរបស់ខ្លួន" និក្ខេបបទថ្នាក់បណ្ឌិតវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យ ប៉ារីស 05-1959 | សហមេធាវីនាំមុខ/វេណី | 00767387(KH); 002023575 (FR); (EN ERN number incomplete) 00767441(KH); 00750636(EN); 00236643(FR); 00767296(KH); 00750555(EN); 00236473(FR) |
| D368/2 | | កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី CHAO Khim ចៅឃីម | សហមេធាវីនាំមុខ/វេណី | |
| D199/14 | | កំណត់ហេតុនៃការស្តាប់ចម្លើយ LEFEUVRE Martine | សហមេធាវីនាំមុខ/វេណី | |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា (១២.០៣) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការសម្រាប់ពេលរសៀល និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោត

ទស្សន៍ទៅបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។

- អង្គជំនុំជម្រះសម្រេចទទួលយកនូវបញ្ជីឯកសាររបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១២ មិនមែនបញ្ជីឯកសារចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១២ នោះទេ ព្រោះឯកសារចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១២ ជាឯកសារមួយដែលបានជូនដំណឹងយ៉ាងសមរម្យដល់ភាគីទាំងអស់ ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩.០០ ព្រឹក ថ្ងៃ សុក្រ ទី ១៩ ខែ តុលា ឆ្នាំ ២០១២។

| <u>កាលបរិច្ឆេទបន្តសវនាការ៖</u> |
| --- |
| សវនាការនឹងបន្តនៅថ្ងៃ សុក្រ ទី ១៩ ខែ តុលា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី១៨ ខែ តុលា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

ឌុច ផារី Roger PHILLIPS